រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ:៤៧៧៧០ ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
# ស្ដីពី
# ការកែសម្រួលសមាសភាពក្រុមប្រឹក្សាប្រឡងប្រណាំង អនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ០១ គនប ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពី "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព"
- យោងប្រកាសលេខ ៩៣១ ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមប្រឹក្សាប្រឡងប្រណាំងអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ
- យោងតាមសំណូមពរនៃការងារ

## សម្រេច

**ប្រការ១.**

កែសម្រួលសមាសភាពក្រុមប្រឹក្សាប្រឡងប្រណាំងសម្រាប់ពិនិត្យលក្ខណសម្បត្តិអង្គភាព និងបុគ្គលដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម សន្តិបណ្ឌិត **ម៉ៅ ចន្ទតារា** | រដ្ឋលេខាធិការប្រចាំការ | ប្រធាន |
| ២. ឯកឧត្តម **យុន ឈុន្នី** | រដ្ឋលេខាធិការ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. ឯកឧត្តម សន្តិបណ្ឌិត **ចាន់ រ៉ាន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤. ឯកឧត្តម សន្តិបណ្ឌិត **សុខ ផល** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៥. លោកជំទាវ **ជូ ប៊ុនអេង** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៦. ឯកឧត្តម **រាជ សុភន្ទ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៧. ឯកឧត្តម **ប្រាក់ សំអឿន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៨. ឯកឧត្តម **ភង សុខន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៩. ឯកឧត្តម សន្តិបណ្ឌិត **គៀត ចន្ទថារិទ្ធ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ១០. ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉ោ ភក្តិ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ១១. ឯកឧត្តម នាយឧត្តមសេនីយ៍ **ស ថេត** | អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធាន |
| ១២. ឯកឧត្តម នាយឧត្តមសេនីយ៍ **សេង យូអ៊ាន់** | អគ្គនាយក នៃអគ្គនាយកដ្ឋាន ភស្តុភារ និងហិរញ្ញវត្ថុ | សមាជិក |
| ១៣. ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **សេង ផល្លី** | អគ្គនាយក នៃអគ្គនាយកដ្ឋាន ធនធានមនុស្ស | សមាជិក |
| ១៤. ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **ឯក មនោសែន** | ប្រធានបណ្ឌិត្យសភា នគរបាលកម្ពុជា | សមាជិក |
| ១៥. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ផាត សុផានិត** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន | សមាជិក |
| ១៦. ឯកឧត្តម **សួស ឆ្រាថ្លា** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ១៧. ឯកឧត្តម ឧត្តមសេនីយ៍ឯក **សុខ វាសនា** | អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ១៨. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឌុប នេត** | អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | សមាជិក |
| ១៩. ឯកឧត្តម **ហ៊ិន យុវនា** | ប្រធានក្រុមប្រឹក្សានីតិកម្ម | សមាជិក |
| ២០. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខួន ស្រេង** | អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ២១. ឯកឧត្តម ឧត្តមអគ្គានុរក្ស.១ **ឈន សារណាត** | អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ | សមាជិក |
| ២២. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឯម វិចិត្រ** | អគ្គាធិការ នៃអគ្គាធិការដ្ឋាន | សមាជិក |
| ២៣. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហោ សំអាត** | អគ្គនាយក នៃអគ្គនាយកដ្ឋាន បច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ | សមាជិក |
| ២៤. លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៊ុណ្ណ សំខាន់** | អគ្គលេខាធិការ គ.ជ.ប.ជ | សមាជិក |
| ២៥. ឯកឧត្តម នាយឧត្តមសេនីយ៍ **មាស វីរិទ្ធ** | អគ្គលេខាធិការ អ.ជ.ប.គ.ញ | សមាជិក |
| ២៦. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឆាយ គឹមខឿន** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ២៧. ឯកឧត្តម **ឈឹម ភាន** | អគ្គនាយករង និងជាប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ នៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |

២៨. ឯកឧត្តម **មួន មោទ** ប្រធាននាយកដ្ឋានមុខងារ និងធនធាន នៃអគ្គនាយកដ្ឋានរដ្ឋបាល សមាជិក

២៩. លោក **ឆាទ ច័យ** ប្រធាននាយកដ្ឋានរដ្ឋបាលសរុប នៃអគ្គនាយកដ្ឋានរដ្ឋបាល សមាជិក

៣០. លោក **លី យ៉ាសាក់** ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នៃអគ្គនាយកដ្ឋានរដ្ឋបាល សមាជិក

**ប្រការ២.** _

ក្រុមប្រឹក្សាប្រឡងប្រណាំងរបស់ក្រសួងមហាផ្ទៃ មានភារកិច្ចដូចខាងក្រោម៖

- កសាងផែនការជំរុញ និងបំផុសចលនាប្រឡងប្រណាំងដណ្ដើមស្នាដៃក្នុងការអនុវត្តលក្ខណសម្បត្តិទី១ ទី២ ទី៣ និងទី៤ នៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដែលស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃឱ្យបានទូលំទូលាយ
- រៀបចំគោលការណ៍ នីតិវិធី ឬសូចនាករនៃលក្ខណសម្បត្តិ ដើម្បីដំណើរការចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- ណែនាំផ្សព្វផ្សាយដល់ក្រុមប្រឹក្សាប្រឡងប្រណាំងគ្រប់លំដាប់ថ្នាក់អំពីការរៀបចំសំណុំបែបបទនិងលក្ខណវិនិច្ឆ័យក្នុងការពិនិត្យលក្ខណសម្បត្តិអង្គភាព និងបុគ្គល ដែលត្រូវផ្ដល់ការលើកសរសើរជូនរង្វាន់
- តាមដានពិនិត្យសកម្មភាពការងាររបស់ក្រុមប្រឹក្សាប្រឡងប្រណាំងគ្រប់លំដាប់ថ្នាក់ ដើម្បីធានាបាននូវយុត្តិធម៌ និងតម្លាភាពក្នុងការផ្ដល់ការលើកសរសើរជូនរង្វាន់ សំដៅរក្សាឱ្យបានសុក្រឹតភាព និងតម្លៃនៃរូបភាពសរសើរ
- ប្រជុំពិភាក្សា ពិនិត្យ វាយតម្លៃ និងកំណត់សម្រេចជ្រើសរើសអង្គភាព និងបុគ្គលដែលមានស្នាដៃឆ្នើមក្នុងចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដែលស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ ដើម្បីស្នើសុំគោលការណ៍ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាលកម្ពុជាពិនិត្យសម្រេចផ្ដល់លិខិតសរសើរ ប័ណ្ណសរសើរ គ្រឿងឥស្សរិយយសជូនឱ្យ សមស្របទៅតាមទំហំស្នាដៃដែលសម្រេចបាន
- បូកសរុបលទ្ធផលការងារប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដែលស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃតាមការកំណត់
- ពិនិត្យជ្រើសរើសកំណត់ចំនួនអង្គភាព និងបុគ្គលដែលទទួលបានគ្រឿងឥស្សរិយយសដើម្បីចូលរួមទទួលការបំពាក់ជូនក្នុងពិធីមិទ្ទិងអបអរសាទររំលឹកខួបអនុស្សាវរីយ៍ថ្ងៃកំណើតនគរបាលជាតិ និងពិធីផ្សេងៗទៀតតាមការកំណត់របស់ក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាលកម្ពុជា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ៣.** _

ត្រូវបានកែសម្រួលសមាសភាពលេខាធិការដ្ឋាននៃក្រុមប្រឹក្សាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ ដើម្បីធ្វើជាសេនាធិការ ដូចខាងក្រោម៖

១. ឯកឧត្តម **យុន ឈុន្នី** រដ្ឋលេខាធិការ ប្រធាន

២. ឯកឧត្តម **សួស ច្រាផ្លា** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អនុប្រធាន

៣. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឆាយ គីមខឿន** អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អនុប្រធាន

៤. ឯកឧត្តម **ឈឹម កាន** អគ្គនាយករង និងជាប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ នៃអគ្គនាយកដ្ឋានរដ្ឋបាល អនុប្រធាន

៥. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ណុប ទី** អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អនុប្រធាន

៦. ឯកឧត្តម ឧត្តមសេនីយ៍ឯក **សាយ ម៉េងឈាង** អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អនុប្រធាន

៧. ឯកឧត្តម **ម៉ែន ប៊ុនរិទ្ធ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន អនុប្រធាន

៨. លោក ឧត្តមសេនីយ៍ទោ **សាង សុធន** អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អនុប្រធាន

៩. ឯកឧត្តម **ប្ញូន ហេង** ប្រធាននាយកដ្ឋានមុខងារ និងធនធាននៃអគ្គនាយកដ្ឋានរដ្ឋបាល សមាជិក

១០. លោក ឧត្តមសេនីយ៍ឯក **ខេង ជួ** ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១១. លោក ឧត្តមសេនីយ៍ឯក **ហេង ចាន់ធារី** ប្រធាននាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១២. លោក **លី យ៉ាសាក់** ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នៃអគ្គនាយកដ្ឋានរដ្ឋបាល សមាជិក

១៣. លោក ឧត្តមសេនីយ៍ទោ **ចាន់ សម្បត្តិ** ប្រធាននាយកដ្ឋានសរុប ផែនការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១៤. លោក ឧត្តមសេនីយ៍ទោ **យឹង សារ៉ាត់** នាយកមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១៥. លោក ឧត្តមសេនីយ៍ទោ **មាស លឹមគុង** ប្រធាននាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១៦. លោកស្រី ឧត្តមសេនីយ៍ទោ **ស៊ឹម ផាណាំ** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១៧. លោក **ឆាង ច័យ** ប្រធាននាយកដ្ឋានរដ្ឋបាលសរុប នៃអគ្គនាយកដ្ឋានរដ្ឋបាល សមាជិក

១៨. លោក ឧត្តមសេនីយ៍ឯក **ជា សុផាត** ប្រធាននាយកដ្ឋានបុគ្គលិកមន្ត្រីនគរបាលជាតិ

| | | |
|---|---|---|
| | នៃអគ្គនាយកដ្ឋានធនធានមនុស្ស | សមាជិក |
| ១៩. លោក ឧត្តមសេនីយ៍ទោ **ខួន ផេងសែ** | អនុប្រធាននាយកដ្ឋានសរុប ផែនការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ២០. លោក វរសេនីយ៍ឯក **ឆាយ ម៉េងហ៊** | អនុប្រធាននាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |

**ប្រការ៤.**_

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទឱ្យជួយបំពេញការងារតាមការចាំបាច់។

**ប្រការ៥.**_

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ធ្វើសេនាធិការជូនក្រសួងមហាផ្ទៃក្នុងការតាមដានត្រួតពិនិត្យការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ព្រមទាំងផ្ដើមស្នើគោលការណ៍ វិធានការនានាជូនក្រសួងមហាផ្ទៃ ដើម្បីជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ
- ជួយក្រសួងមហាផ្ទៃក្នុងការផ្សព្វផ្សាយផែនការ គោលការណ៍ផ្សេងៗរបស់ក្រសួងមហាផ្ទៃឱ្យទៅអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ដែលមានការពាក់ព័ន្ធ និងក្រុមប្រឹក្សាដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ
- រៀបចំកិច្ចប្រជុំ និងបំពេញកិច្ចការរដ្ឋបាលពាក់ព័ន្ធដល់ការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ និងបូកសរុបសភាពការណ៍ និងលទ្ធផលនៃការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ក្នុងក្របខ័ណ្ឌទូទាំងប្រទេសតាមដំណាក់កាលនីមួយៗជូនក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល
- រៀបចំគម្រោងថវិកា មធ្យោបាយ សម្ភារៈបម្រើដល់ការចាត់តាំងអនុវត្តជូនក្រសួងមហាផ្ទៃពិនិត្យ សម្រេច
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ៦.**_

ត្រូវបានបង្កើតក្រុមប្រឹក្សាប្រឡងប្រណាំងរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. អភិបាល និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត | ប្រធាន |
| ២. អភិបាលរង ០១រូប នៃគណៈអភិបាលរាជធានី ខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. នាយករដ្ឋបាលសាលារាជធានី ខេត្ត | អនុប្រធាន |
| ៤. ស្នងការ នៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត | អនុប្រធាន |

៥. ប្រធានមន្ទីរ អង្គភាពនានាជុំវិញរាជធានី ខេត្ត សមាជិក

៦. អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ សមាជិក

**ប្រការ៧.** _

ក្រុមប្រឹក្សាប្រឡងប្រណាំងរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវបង្កើតលេខាធិការដ្ឋាន ដើម្បីធ្វើជាសេនាធិការ និងត្រូវបង្កើតក្រុមប្រឹក្សាប្រឡងប្រណាំងរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់។ សមាសភាពលេខាធិការដ្ឋាន និងក្រុមប្រឹក្សាប្រឡងប្រណាំងរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអភិបាល និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត។

**ប្រការ៨.** _

ក្រុមប្រឹក្សាប្រឡងប្រណាំងរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត មានភារកិច្ចដូចខាងក្រោម៖

- លើកផែនការទិសដៅបំផុសចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដល់អង្គភាពក្រោមឱវាទ ដើម្បីរៀបចំផែនការសកម្មភាពអនុវត្ត
- ណែនាំផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព»ដល់មន្ត្រីរាជការ កងកម្លាំងមានសមត្ថកិច្ច ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល វិស័យឯកជន និងសហគមន៍នៅមូលដ្ឋាន ដើម្បីលើកកម្ពស់ការយល់ដឹង និងចូលរួមអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» និងចូលរួមចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ព្រមទាំងផ្តល់នូវការលើកសរសើរជូនរង្វាន់
- គ្រប់គ្រង ចាត់ចែង ត្រួតពិនិត្យ កសាងពង្រឹង បណ្តុះបណ្តាល និងគាំទ្រទាំងស្មារតី សម្ភារ ដល់ចលនាប្រជាការពារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ប្រជុំបូកសរុប ពិនិត្យ វាយតម្លៃជ្រើសរើសអង្គភាព និងបុគ្គលដែលស្ថិតក្នុងសមត្ថកិច្ចដើម្បីលើកសំណើសុំទៅក្រុមប្រឹក្សាប្រឡងប្រណាំងរបស់ក្រសួងមហាផ្ទៃ ផ្តល់រូបភាពសរសើរជូនឱ្យបានសមស្របទៅតាមទំហំស្នាដៃដែលសម្រេចបាន
- តាមដានជំរុញត្រួតពិនិត្យជាប្រចាំចលនាប្រឡងប្រណាំងស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួនសម្រាប់ជាមូលដ្ឋានផ្តល់ការលើកសរសើរជូនរង្វាន់ដល់អង្គភាព បុគ្គលដែលមានស្នាដៃឆ្នើមប្រកបដោយតម្លាភាព និងយុត្តិធម៌ សំដៅរក្សាឱ្យបានសុក្រឹតភាព និងតម្លៃនៃរូបភាពសរសើរ
- ដកស្រង់បទពិសោធន៍ពីអង្គភាព និងបុគ្គលមានស្នាដៃឆ្នើមដែលទទួលបានការលើកសរសើរជូនរង្វាន់ ដើម្បីផ្សព្វផ្សាយដល់អង្គភាព និងបុគ្គលដែលពុំទាន់ធ្លាប់ទទួលបានរូបភាពសរសើរ សំដៅលើកកម្ពស់ប្រសិទ្ធភាពចលនាប្រឡងប្រណាំងអនុវត្តតាមគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ឱ្យកាន់តែសកម្មផុលផុស
- ពិនិត្យជ្រើសរើសអង្គភាព និងបុគ្គលដែលទទួលបានការលើកសរសើរជូនរង្វាន់ដែលមានស្នាដៃឆ្នើមបំផុត និងមានបទពិសោធន៍ល្អៗក្នុងការបំពេញភារកិច្ចអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» រាយការណ៍ជូនក្រុមប្រឹក្សាប្រឡងប្រណាំងរបស់ក្រសួងមហាផ្ទៃ ដើម្បីផ្តល់កិត្តិយសចូលរួមក្នុងពិធីមិទ្ទីងអបអរសាទររំលឹកខួបអនុស្សាវរីយ៍ថ្ងៃកំណើតនគរបាលជាតិកម្ពុជា និងពិធីផ្សេងៗទៀតតាមការកំណត់របស់ក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាលកម្ពុជា

- ធ្វើការពិគ្រោះយោបល់ជាមួយក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានលើដំណើរការចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- បូកសរុបលទ្ធផលការងារប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» រាយការណ៍ជូនក្រុមប្រឹក្សាប្រឡងប្រណាំងរបស់ក្រសួងមហាផ្ទៃ
- បំពេញភារកិច្ចផ្សេងៗទៀតតាមចាំបាច់។

**ប្រការ៩.** _

ក្នុងករណីដែលមានការផ្លាស់ប្តូរតួនាទីក្នុងមុខងារសាធារណៈនៅតាមរាជធានី ខេត្ត មន្ត្រីថ្នាក់ដឹកនាំដែលចូលមកកាន់មុខតំណែងថ្មីជំនួស មានភារកិច្ចទទួលខុសត្រូវលើមុខតំណែងក្នុងក្រុមប្រឹក្សាប្រឡងប្រណាំងដូចមានចែងក្នុងប្រការ៦ ខាងលើ ជាស្វ័យប្រវត្តិ។

**ប្រការ១០.** _

ប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ៩៣១ ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមប្រឹក្សាប្រឡងប្រណាំងអនុវត្តគោលនយោបាយ "ភូមិ- ឃុំ-សង្កាត់មានសុវត្ថិភាព"ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ ត្រូវជំនួសដោយប្រកាសនេះ។

**ប្រការ១១.** _

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២.** _

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស អគ្គនាយកនៃអគ្គនាយកដ្ឋាន បច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំ គ្រប់នាយកដ្ឋាន-អង្គភាពពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ និងប្រការ៣ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ សុក្រ ៧រោច ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១២
- រាជកិច្ច